00548886

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ

Pre-Trial Chamber
Chambre Préliminaire

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ)

| | |
|---|---|
| ចំពោះមុខ: | **ចៅក្រម ប្រាក់ គីមសាន, ប្រធាន** |
| | **ចៅក្រម Rowan DOWNING** |
| | **ចៅក្រម និយ ថុល** |
| | **ចៅក្រម Catherine MARCHI-UHEL** |
| | **ចៅក្រម ហួត វុទ្ធី** |
| កាលបរិច្ឆេទ: | ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ |

---

**សាធារណៈ**

**សេចក្តីព្រមានចំពោះការផ្សព្វផ្សាយព័ត៌មានសម្ងាត់ដោយគ្មានការអនុញ្ញាត**

---

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

យ៉ែត ចរិយា

William SMITH

**ជនត្រូវចោទ**

នួន ជា

អៀង សារី

អៀង ធីរិទ្ធ

ខៀវ សំផន

កាំង ហ្កេកអ៊ាវ

**មេធាវីនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី**

នី ចាន់ឌី

Mahdev MOHAN
Lyma NGUYEN

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

Elizabeth-Joelle RABESANDRATANA
Annie DELAHAIE
Phillipe CANONNE

**សហមេធាវីការពារក្តី**

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៨១៤ ទូរសារ (៨៥៥) ២៣ ២១៩ ៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, Phnom Penh, Cambodia, PO Box 71, Tel: (855) 23 219 814 Fax: (855) 23 219 841 Web: www.eccc.gov.kh

00548887



Martine JACQUIN
Fabienne TRUSSES-NAPROUS
Francoise GAUTRY
Isabelle DURAND
Christine MARTINEAU
Laure DESFORGES
Ferdinand DJAMMEN-NZEPA

ឡៅ ជុនធី

ស៊ិន សុវ៉ន

សំ សុគង់

ហុង គីមសួន

គង់ ពិសី

គង់ ហេង

Silke STUDZINSKY
Olivier BAHOUGNE
Marie GUIRAUD
Patrick BAUDOIN

ជេត វណ្ណលី

ពេជ អង្គ

Julien RIVET
Pascal AUBOIN

យ៉ុង ផានិត

**ដើមបណ្តឹងរដ្ឋប្បវេណីគ្មានអ្នកតំណាង**

ផាត់ ពៅស៊ាង
Diana ELLIS

ស ស្វាន
Jacques VERGES
Philippe GRECIANO

ការ សាវុត្ថ
François ROUX

**សហចៅក្រមស៊ើបអង្កេត**

យូ ប៊ុនឡេង
Marcel LEMONDE

00548888

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(“អ.វ.ត.ក”)សង្កេតឃើញថា មានអត្ថបទចំនួនពីរដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងសារព័ត៌មាន *ឌឹ ខេមបូឌា ដេលី* (*The Cambodia Daily*) ដែលមានព័ត៌មានសម្ងាត់ទាក់ទងទៅនឹងបញ្ហាមួយចំនួន ដែលបញ្ហាទាំងនោះ អង្គបុរេជំនុំជម្រះទើបតែបានទទួលនៅពេលថ្មីៗនេះ(“បញ្ហា”)[១]។

១. អង្គបុរេជំនុំជម្រះសូមរំលឹកដល់រាល់ភាគីនៃសំណុំរឿង ០០២ ទាំងអស់ថា៖

ក) ភាគីដាក់ឯកសារអាចស្នើថា ឯកសារណាមួយអាចត្រូវបានចាត់ប្រភេទថា ជាឯកសារ “សាធារណៈ” ដោយអនុលោមតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងទៅនឹងសំណុំរឿង។ ទោះជាយ៉ាងនេះក៏ដោយ អង្គបុរេជំនុំជម្រះត្រូវពិចារណា ថាតើចំណាត់ប្រភេទឯកសារដែលស្នើឡើងនោះមានភាពសមស្របដែរឬទេ ហើយប្រសិនបើមិនមានភាពសមស្របទេនោះ អង្គបុរេជំនុំជម្រះ ត្រូវកំណត់ប្រភេទឯកសារនោះឱ្យបានសមស្រប រហូតទាល់តែមានដីកាដំណោះស្រាយ ហើយបណ្តឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាដំណោះស្រាយនោះ ត្រូវបានដោះស្រាយរួច[២]។

ខ) ជាគោលការណ៍ រាល់ឯកសារដែលដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះទាំងអស់ គឺជាឯកសារសម្ងាត់ លុះត្រាណាមានការសម្រេចលើបញ្ហានេះ ដោយអង្គបុរេជំនុំជម្រះ។ ឯកសារទាំងនោះអាចត្រូវបានចាត់ប្រភេទផ្សេងណាមួយ ដោយអនុលោមតាមសេចក្តីសម្រេចរបស់តុលាការ[៣]។

[១] អត្ថបទរបស់លោក ឌូហ្គាស ហ្គៀលលីសឹន (Douglas Gillison) “មេធាវីរបស់លោក អៀង សារី ជម្រុញឱ្យតុលាការសួរទៅខាងរដ្ឋាភិបាល” ចុះផ្សាយនៅក្នុងសារព័ត៌មាន *ឌឹ ខេមបូឌា ឌេលី* នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១០ លេខ ៤៥/៨៦ ទំព័រទី ២០។ អត្ថបទរបស់លោក ឌូហ្គាស ហ្គៀលលីសឹន “ក្រុមមេធាវីរបស់លោក នួន ជា ចោទប្រកាន់ថាលោក យូ ប៊ុនឡេង មានភាពលំអៀងខាងនយោបាយ” ចុះផ្សាយនៅក្នុងសារព័ត៌មាន *ឌឹ ខេមបូឌា ឌេលី* នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០ លេខ ៤៥/៩០ ទំព័រទី ៣០។

[២] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ឯកសារលេខ អវតក/០១/២០០៧/វិសោធនកម្មលើកទី៤ មាត្រា ៣.១២ http://www.eccc.gov.kh/khmer/cabinet/courtDoc/312/PD_Filing_Revision_4_final_Kh.pdf។

[៣] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ឯកសារលេខ អវតក/០០៤/២០០៩ មាត្រា ៥.១.ជ http://www.eccc.gov.kh/khmer/cabinet/courtDoc/313/PD_Classification_Body_Kh.pdf។

គ)   អង្គបុរេជំនុំជម្រះបានសម្រេចថា ចំណាត់ប្រភេទដ៏សមស្រប សម្រាប់បញ្ហាទាំងនោះ គឺ "សម្ងាត់"។

ឃ)   "សម្ងាត់" "មានន័យថា បើកចំហជូនចំពោះតែចៅក្រម សហព្រះរាជអាជ្ញា មេធាវីភាគីដើមបណ្ដឹង មេធាវីការពារក្ដី បុគ្គលិកតុលាការដែលមានសិទ្ធិ និងអ្នកទាំងឡាយណាដែលទទួលបានសិទ្ធិពិនិត្យមើលឯកសារ តាមសេចក្ដីសម្រេចរបស់តុលាការជាមុន"[៤]។ អង្គបុរេជំនុំជម្រះមិនបានផ្ដល់សិទ្ធិឱ្យសារព័ត៌មាន *ឌឺ ប៉ែមបូឆា ដេលី* ទទួលបានផ្នែកណាមួយនៃបញ្ហាទាំងនោះឡើយ។

ង)   ភារកិច្ចរក្សាការសម្ងាត់ មានចែងដូចខាងក្រោម៖

> ជនគ្រប់រូបដែលមានសិទ្ធិពិនិត្យមើលព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត ត្រូវតែគោរពគោលការណ៍នៃការរក្សាការសម្ងាត់។ ពួកគេមិនត្រូវផ្សព្វផ្សាយព័ត៌មានបែបនេះទៅឱ្យនរណាម្នាក់ លើកលែងតែអនុលោមតាមសេចក្ដីណែនាំអនុវត្តនេះ។ លើសពីនេះទៀត ពួកគេមិនត្រូវប្រព្រឹត្តក្នុងរូបភាពណាក៏ដោយ ដែលនឹងបណ្ដាលឱ្យលេចឮព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត ដោយគ្មានការអនុញ្ញាតនោះទេ[៥]។

ការរំលោភបំពានលើភារកិច្ចនេះនឹងទទួលបាននូវការដាក់ទណ្ឌកម្ម ដោយអនុលោមតាមវិធានផ្ទៃក្នុង[៦]។

ច)   ដោយអនុលោមតាមវិធាន៥៦(១)"បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរ ត្រូវរក្សាឱ្យបាននូវការសម្ងាត់"។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ ចេញសេចក្ដីព្រមានដូចខាងក្រោម៖**

១.   ដោយអនុលោមតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដក្នុងកិច្ចការ

---

[៤] សេចក្ដីណែនាំអនុវត្តស្ដីពីការចាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង មាត្រា ២.ឃ.ii។

[៥] សេចក្ដីណែនាំអនុវត្តស្ដីពីការចាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង មាត្រា ៨.១។

[៦] សេចក្ដីណែនាំអនុវត្តស្ដីពីការចាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង មាត្រា ១១។

រដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលផ្សាយចេញព័ត៌មានសម្ងាត់ ដោយមិនអនុលោមតាមសេចក្ដីណែនាំអនុវត្តស្ដីពីការចាត់ប្រភេទ និងគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ឬ បុគ្គលណាដែលរំលោភបំពានលើវិធាន ៥៦(១) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួររបស់តុលាការនោះ។

២. ដោយអនុលោមតាមវិធាន៣៨(១)-(២) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះ ក្រោយពេលព្រមានអាចដាក់ទណ្ឌកម្ម ឬបដិសេធមិនឱ្យមេធាវីចូលរួមសវនាការ ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះ ជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភទៅលើរឿងក្ដី ឬ ផ្ទុយទៅនឹងមាត្រា ២១(៣) នៃកិច្ចព្រមព្រៀង។ អង្គបុរេជំនុំជម្រះក៏អាចបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះទៅអង្គភាពមានសមត្ថកិច្ចផងដែរ។

ភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០

ប្រធានអង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

ប្រាក់ គឹមសាន